# ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ ១៦ III ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០

សាលដីកានេះអាចរកបាននៅ៖SC.16(24.01.2020) (measboralaws.com)

**ពាក្យគន្លឹះ៖** រំលោភលើទំនុកចិត្ត, ភស្តុតាង, ធាតុផ្សំនៃការសមគំនិត

## ១. អង្គហេតុនិងនីតិវិធី

ប្រធានទីផ្សារ (ប្តីមានអាយុ២៨ឆ្នាំ) បានយកលុយក្រុមហ៊ុនទៅឲ្យប្រពន្ធទិញផ្ទះ ហើយបានគេចខ្លួន។ ប្រពន្ធបានធ្វើលិខិតលែងលះ ដើម្បីបង្វែរពីទ្រព្យរួម។ អង្គហេតុនេះ ត្រូវបានចោទពីបទរំលោភលើទំនុកចិត្ត និងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅក្នុងខែឧសភា ឆ្នាំ២០១៥ តាមមាត្រា២៩, ៣៩១និង ៣៩២នៃក្រមព្រហ្មទណ្ឌ។ សាលក្រមតុ.ភ្នំពេញលេខ៣៤៣៧ ខែធ្នូឆ្នាំ២០១៧ បានដាក់ទោសប្តី១៨ខែពីបទរំលោភលើទំនុកចិត្ត និងប្រពន្ធទោស៦ខែពីបទសមគំនិតបទនេះ និងរួមគ្នាសងសំណង ១២០០០០ (ដូចគ្នានឹងប្រាក់ក្រុមហ៊ុនបាត់) និងជំងឺចិត្ត១០លានរៀល។ ជនជាប់ចោទប្តឹងឧទ្ធរណ៍ ហើយសាលានេះបានតម្កល់សាលក្រមលេខ៣៤៣៧ (សាលដីកាលេខ២២០ កុម្ភៈ ឆ្នាំ២០១៩)។ ជនជាប់ចោទបានប្តឹងសាទុក្ខ។

### តុលាការកំពូល៖....

២-*យល់ឃើញថា....សំអាងហេតុនេះពុំមានមូលដ្ឋានអង្គហេតុ ភស្តុតាងសមស្រប ដើម្បីកំណត់ពិរុទ្ធភាពលើជនជាប់ចោទ* (ប្រពន្ធ)*...នោះទេ ពីព្រោះថាតាមបទបញ្ញត្តិមាត្រា២៩...ជាអ្នកសមគំនិតក្នុងអំពើល្មើសណាមួយ លុះត្រាជននោះបានជួយសម្រួលដោយចេតនា ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភជាមុនឬក្នុងពេលដែលចារីប្រព្រឹត្តបទល្មើស ..ប៉ុន្តែក្នុងរឿងក្តីនេះពុំមានភស្តុតាងណាមួយដែលបញ្ជាក់...*

៣-*យល់ឃើញថា...កិច្ចសន្យាលក់ទិញផ្ទះ និងទំនាក់ទំនងអាពាហ៍ពិពាហ៍ មិនមែនជាភស្តុតាងបញ្ជាក់អំពីអំពើសមគំនិតក្នុងបទល្មើសរំលោភលើទំនុកចិត្តនោះទេ។...យោងតាមបទប្បញ្ញត្តិមាត្រា៣៨នៃរដ្ឋធម្មនុញ្ញ...*។

**សម្រេច៖** ...២-*បដិសេធសាលដីកាលេខ២២០...*។៣-*ឲ្យជនជាប់ចោទ...រួចខ្លួនពីបទចោទប្រកាន់...*។ ៤-*ឲ្យជនជាប់ចោទ....រួចផុតពីការទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី*។

## ២. កំណត់សំគាល់

**១.** គិតពីឆ្នាំកើតហេតុ មកដល់ឆ្នាំចេញសាលដីកា មានរយៈពេលប្រហែល៥ឆ្នាំ។ មាត្រា២៩ ចែងថាចារីនិងជនសមគំនិតត្រូវផ្តន្ទាទោសដូចគ្នា។ ក្នុងសំណុំរឿងនេះទោសសម្រាប់អ្នកសមគំនិតស្រាលជាងចារី។

**២.** តុលាការកំពូលបានបន្ថែមខ្លឹមសារ ជួយ"*ជាមុនឬក្នុងពេលដែលចារីប្រព្រឹត្ត*" បំភ្លឺខ្លឹមសារការសមគំនិត។ នេះអាចជួយចែកដាច់ពីបទទទួលផលចោរកម្ម ដែលការជួយកើតក្រោយពេល ដែលបទលួច

ត្រូវបានប្រព្រឹត្តរួចទៅហើយ។ សម្រាប់ខ្លឹមសារលម្អិតអំពីធាតុផ្សំនៃការសមគំនិត សូមមើលសាលដីកាតុលាការកំពូលលេខ១៨៣ Measboralaws។

៣. តុលាការសម្រេចក្ដីផ្អែកលើភស្តុតាង។ ក្នុងសំណុំរឿងនេះ សម្រាប់ចោទបទសមគំនិតក្នុងបទរំលោភលើទំនុកចិត្ត ភស្តុតាងអំពីចំណាងអាពាហ៍ពិពាហ៍តែមួយមុខមិនគ្រប់គ្រាន់ទេ។

៤. តាមខ្លឹមសារនៃសាលដីកានេះ កាលណាមានមន្ទិលខ្លាំងអំពីការប្រព្រឹត្តរបស់ជនជាប់ចោទមន្ទិលនឹងជាប្រយោជន៍សម្រាប់ជនជាប់ចោទ សន្មត់ថាគាត់មិនបានប្រព្រឹត្ត។ ដូចនេះ តុលាការកំពូលនឹងបដិសេធសាលដីកាដាក់ទោស និងសម្រេចរួចផុតពីបទចោទចោទប្រកាន់ អនុលោមតាមមាត្រា៤៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌ។